# រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី
# ឯកឧត្តម ព្រឹទ្ធសមាជិក បប់ ខារ
# **សេចក្តីប្រកាសព័ត៌មាន**
# ១៣ កក្កដា ២០១២

## **អូស្ត្រាលីនឹងបើកសន្និសីទជាន់ខ្ពស់ស្តីអំពីជំងឺគ្រុនចាញ់**

រដ្ឋាភិបាលអូស្ត្រាលី នឹងបើកសន្និសីទជាន់ខ្ពស់មួយនៅខែតុលាដើម្បីជួយដោះស្រាយនូវបញ្ហាប្រឈមនៃជំងឺគ្រុនចាញ់។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី បប់ ខារ បានប្រកាសអំពីសន្និសីទជំងឺគ្រុនចាញ់ឆ្នាំ២០១២៖ សន្និសីទតំបន់អាស៊ីប៉ាស៊ីហ្វិកដើម្បីសង្គ្រោះជីវិត នៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្នុងកិច្ចប្រជុំកំពូលអាស៊ីបូំពានៅប្រទេសកម្ពុជាកាលពីម្សិលមិញនេះ។

ឯកឧត្តម ព្រឹទ្ធសមាជិក ខារ មានប្រសាសន៍ទៀតថា៖ "ទោះបីជាមានការវិវឌ្ឍន៍ថ្មីៗក្នុងការប្រយុទ្ធប្រឆាំងនិងជំងឺគ្រុនចាញ់ក៏ពិតមែន ក៏ប៉ុន្តែនៅមានជំងឺគ្រុនចាញ់ជាង២០០លានករណីកើតឡើងនៅលើសកលលោក ក្នុងនោះមានជាង៣០លានករណីកើតឡើងនៅក្នុងតំបន់របស់យើង។"

ជំងឺគ្រុនចាញ់ជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើជនក្រីក្រមួយចំនួន និងជនដែលងាយរងគ្រោះបំផុតនៅក្នុងតំបន់របស់យើងជំងឺនេះបានសម្លាប់មនុស្ស៤ម៉ឺនពីរពាន់នាក់កាលពីឆ្នាំ២០១០ ហើយបានបន្សល់ទុកនូវមនុស្សជាច្រើននាក់ទៀតដែលមិនអាចធ្វើការបាន ហើយក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរដល់ក្រុមគ្រួសាររបស់ពួកគេ។ ជំងឺគ្រុនចាញ់ក៏គំរាមកំហែងដល់កំនើនសេដ្ឋកិច្ច និងផលប្រយោជន៍ពាណិជ្ជកម្មក្នុងតំបន់ផងដែរ។

ឯកឧត្តម ព្រឹទ្ធសមាជិក ខារ បន្តទៀតថា " ការលេចចេញនូវជំងឺគ្រុនចាញ់ដែលស៊ាំនិងថ្នាំនៅក្នុងតំបន់បានគំរាមកំហែងដល់ប្រសិទ្ធិភាពនៃកិច្ចប្រឹងប្រែងក្នុងការបង្កើនការគ្រប់គ្រង និងលប់បំបាត់ជំងឺមួយនេះ ។

ការដោះស្រាយបញ្ហាសុខភាពជាសកល ក្លាយជាចំនុចអាទិភាពសំរាប់អូស្ត្រាលី នៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ហើយខ្ញុំរីករាយដែលពួកយើងនឹងបន្តការងារនេះនៅសន្និសីទជំងឺគ្រុនចាញ់នៅចុងឆ្នាំនេះ។

---

សន្និសីទនេះនឹងផ្តល់ឱកាសដល់អ្នកដឹកនាំអាស៊ីប៉ាស៊ីហ្វិកបន្តជោគជ័យរបស់ពួកយើង ក្នុងការការពារនិងបង្កើនការវិវឌ្ឍន៍នៅក្នុងតំបន់ដើម្បីឆ្លើយតបនិងជំងឺគ្រុនចាញ់។

សន្និសីទនេះនឹងផ្តល់ជាវេទិកាសំរាប់ពិភាក្សា ថាតើពួកយើងអាចធ្វើការរួមគ្នាបែបណាដើម្បីប្រឆាំងនិងបញ្ហាដែលលេចឡើងដោយសារភាពស៊ាំនិងថ្នាំដោយមេរោគគ្រុនចាញ់នៅក្នុងតំបន់ និងបន្តស្វែងរកវិធីដើម្បីរួមចំនែកក្នុងកិច្ចប្រឹងប្រែងជាលក្ខណៈតំបន់ ដើម្បីលប់បំបាត់ការស្លាប់ដោយសារជំងឺគ្រុនចាញ់នៅត្រឹមចុងឆ្នាំ២០១៥ ដែលបានអំពាវនាវដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន់ គីម៊ូន។"

អូស្រ្តាលីបាន និងកំពុងតែធ្វើការជាមួយប្រទេសកំពុងអភិវឌ្ឍន៍នានានៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកដើម្បីប្រឆាំងនិងជំងឺគ្រុនចាញ់។បច្ចុប្បន្ននេះអូស្រ្តាលីកំពុងគាំទ្រដល់បណ្តាញលប់បំបាត់ជំងឺគ្រុនចាញ់ក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក និងផ្តល់វិភាគទានក្នុងការជួយសង្រ្គោះជីវិត ក្នុងនោះរួមមានទាំងការផ្តល់ថវិកាក្នុងការព្យាបាលនិង ការចែកចាយមុងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកផងដែរ។

ការគាំទ្ររបស់យើងបានរួមចំនែកធ្វើអោយទទួលបានលទ្ធផលដ៏គួរអោយកត់សម្គាល់ ក្នុងការកាត់បន្ថយជំងឺគ្រុនចាញ់នៅកោះស៊ូលូម៉ុននិង វ៉ានូអាទូ។ ចាប់តាំងពីឆ្នាំ២០០៣មកជំនួយរបស់ពួកយើងបានជួយកាត់បន្ថយករណីជំងឺគ្រុនចាញ់បាន ៧០%នៅកោះស៊ូលូម៉ុន និង ៨៥% នៅវ៉ានូអាទូ។

សន្និសីទជំងឺគ្រុនចាញ់ឆ្នាំ២០១២ នឹងប្រារព្ធឡើងនៅទីក្រុងស៊ីដនី ក្នុងរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី ៣១តុលាដល់ថ្ងៃទី២ វិច្ឆិកា ២០១២។ តំណាងមកពីរដ្ឋាភិបាល និង ដៃគូរអភិវឌ្ឍន៍នានា នៅជុំវិញតំបន់អាស៊ីនិងប៉ាស៊ីហ្វិក នឹងមកចូលរួមសន្និសីទនេះ រួមជាមួយនិងអ្នកជំនាញនាំមុខផ្នែកសុខាភិបាលនិងអភិវឌ្ឍន៍ជាច្រើននាក់ផងដែរ។

រួមជាមួយនឹងព្រឹត្តិការណ៍នេះផងដែរ ឯកឧត្តម ព្រឹទ្ធសមាជិក ខារ នឹងបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្រ្តីជាមួយនិងប្រេសិតពិសេសប្រឆាំងនិងជំងឺគ្រុនចាញ់របស់អង្គការសហប្រជាជាតិ គឺលោក រ៉េយ៍ឆែមបឺស៍។

## ទំនាក់ទំនងសម្រាប់សារព័ត៌មាន

- ការិយាល័យរដ្ឋមន្រ្តី +៦១ ២ ៦២៧៧ ៧៥០០
- ការិយាល័យសម្របសម្រួលព័ត៌មាននៃនាយកដ្ឋានការបរទេសនិងពាណិជ្ជកម្ម +៦១ ២ ៦២៦១ ១៥៥៥
- ការិយាល័យព័ត៌មានរបស់ ទីភ្នាក់ងារ អូស្រ្តាលី ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) +៦១ ៤១៧ ៦៨០ ៥៩០។
- អ្នកនាំពាក្យប្រចាំស្ថានទូតអូស្រ្តាលីនៅរាជធានីភ្នំពេញ +៨៥៥ ១២ ៨១០ ៨០៦។